ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា
LEGAL AID of CAMBODIA
មេធាវី បំរើជនក្រីក្រកម្ពុជា ដោយឥតគិតថ្លៃ
LAWYERS SERVING CAMBODIA'S POOR FREE OF CHARGE

# គោលនយោបាយការពារកុមារ

# របស់

# អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា

ផ្ទះលេខ ៥៧.៥៩ ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥) ៨៦៤ ២០១ ទូរសារ (៨៥៥) ២៣ ៨៦៤២០៣ គេហទំព័រ www.lac.org.kh,
Email:lac@online.com.kh

មាតិការ


១. សេចក្តីណែនាំ

២. គោលបំណង

៣. គោលនយោបាយ

    ៣.១ ទិសដៅ និងគោលបំណង

    ៣.២ វិសាលភាព និងការទំនាក់ទំនង

    ៣.៣ គោលការណ៍ណែនាំ

    ៣.៤ ការអនុវត្តគោលការណ៍នៅក្នុងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

    ៣.៥ ដំណើរការធ្វើសេចក្តីរាយការណ៍តាមអាណត្តិនិមួយៗ

    ៣.៦ បទដ្ឋានសំរាប់បុគ្គលិក និងអង្គការដៃគូដែលពាក់ព័ន្ធ

៤. សន្ទានុក្រម

៥. ឯកសារភ្ជាប់

    ៥.១ លិខិតបទដ្ឋាននានាដែលទាក់ទងនឹងការការពារកុមារ

**៦. សេចក្តីបន្ថែម**

    A. ក្រមសីលធមិការការពារកុមារ

    B. ឯកសារយោងអំពីវាក្យស័ព្ទ និងសេចក្តីបញ្ជាក់លិខិតថ្កោលទោស

    C. របាយការណ៍របស់អ្នកទស្សនាពីការប្តេជ្ញាចិត្ត

    D. ទំរង់បែបបទរាយការណ៍នៃហេតុការ

    E. ទំរង់បែបបទនៃសេចក្តីព្រមព្រៀងលើការថតរូបភាព

១.សេចក្តីផ្តើម

នៅក្នុងគោលនយោបាយនេះពាក្យថា "កុមារ គឺសំដៅលើបុគ្គលណា ដែលមានអាយុក្រោមអាយុ ១៨ឆ្នាំ តាមការបកស្រាយរបស់សន្និបាតអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ (UNCRC)។ កុមារគ្រប់រូបមានសិទ្ធទទួលបានការពារពីការរំលោភបំពាន ការប្រើអំពើហិង្សា និងការកេងប្រវ័ញ្ច។ ដើម្បីឱ្យសមស្របទៅនឹងកិច្ចព្រមព្រៀងស្តីពីសិទ្ធកុមារ អង្គការជំនួយការច្បាប់កម្ពុជា (LAC) ធ្វើការដើម្បីធានាឱ្យបានថា កុមារគ្រប់រូប ជាពិសេស កុមារដែលមិនបានទទួលការថែទាំ និងកុមារដែលងាយរងគ្រោះបំផុត គឺត្រូវបានលើកកម្ពស់នូវការយល់ដឹងពីសិទ្ធរបស់ពួកគេ។ កុមារគ្រប់រូបមានសិទ្ធទទួលបានការពារដូចជា ៖

"ការការពារនូវរាល់ទម្រង់ទាំងឡាយ នៃការប្រើប្រាស់អំពើហិង្សាទាំងផ្នែករាងកាយ និងផ្លូវចិត្ត ការបង្ករបួសស្នាម រឺការរំលោភបំពាន ការមិនយកចិត្តទុកដាក់ រឺការធ្វេសប្រហែស ការធ្វើទុក្ខទោស រឺ ការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ នៅពេលដែលស្ថិតក្នុងការថែទាំរបស់ឪពុកម្តាយ អាណាព្យាបាលស្របច្បាប់ រឺអ្នកថែទាំកុមារ ដោយយោងតាម UNCRC មាត្រាទី ១៩ ៕

អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាធ្វើការពាក់ព័ន្ធចំណុចនេះ គឺដើម្បីបង្កើតឱ្យបាននូវបរិយាកាសមួយប្រកបដោយសុវត្ថិភាពចំពោះកុមារ និងមានគោលបំណងរក្សាសុវត្ថិភាពកុមារ ចៀសផុតពីការកេងប្រវ័ញ្ច និងការរំលោភបំពាន តាមវិធីដែលអាចធ្វើបាន ស្របតាមមាត្រាទី ១៩ របស់ UNCRC ។ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាជឿជាក់ថា រឿងនេះគឺជាទំនួលខុសត្រូវរបស់បុគ្គលគ្រប់រូបទាំងអស់ រួមមាន បុគ្គលិក អ្នកស្ម័គ្រចិត្ត ទីប្រឹក្សា ដៃគូ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ឱ្យយល់ដឹងពីហានិភ័យណាមួយ ដែលអាចកើតឡើងចំពោះកុមារ។ បុគ្គលិកគ្រប់រូបគួរតែចូលរួមអនុវត្តនូវចំណុចទាំងនេះ ដើម្បីកាត់បន្ថយហានិភ័យ និងលើកឡើងនូវបញ្ហា ដែលអាចកើតមានឡើង ជាមួយនឹងក្តីបារម្ភនានាដែលទាក់ទងនឹងកុមារ ដើម្បីស្វែងរកដំណោះស្រាយដ៏សមស្រប ដូចដែលបានចែងក្នុងគោលនយោបាយនេះស្រាប់ ។

២/ គោលបំណង:

គោលនយោបាយនេះផ្តល់នូវទំរង់ការងារមួយដើម្បីការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពាន ក្នុងពេលដែលអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាអនុវត្តសកម្មភាពរបស់ខ្លួន។ គោលនយោបាយនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្រុមអ្នកគ្រប់គ្រង និងក្រុមអ្នកអង្កេតការ ដើម្បីបញ្ជាក់ឱ្យច្បាស់ពីតួនាទីរបស់ខ្លួនស្តីពីការការពារកុមារ ដែលកុមារចាំបាច់ណាស់ត្រូវបានការពារ និងថែរក្សាសុវត្ថិភាព

ពីផលប៉ះពាល់នៃភាពក្រីក្រ ឧបសគ្គ ការរិតត្បិត អំពើហិង្សា និងការរើសអើង។ លើសពីនេះទៀត ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច សង្គម និងនយោបាយ កុមារម្នាក់ៗអាចប្រឈមនឹងគ្រោះថ្នាក់ពីទម្រង់នៃការរំលោភបំពានណាមួយពីសំណាក់មនុស្សពេញវ័យ រឺកុមារដទៃទៀត។

**ក្នុងគោលនយោបាយនេះ:** អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា គឺធ្វើការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនត្រឹមត្រូវចំពោះ:

កុមារដែលមានទំនាក់ទំនងជាមួយនឹង អ្នកតំណាងរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា តាមរយៈកម្មវិធីរបស់អង្គការ ក្នុងកំឡុងពេលអនុវត្តសកម្មភាព។ អ្នកទទួលផលភាគច្រើនរបស់អង្គការ គឺជាកុមារដែលមិនបានទទួលការថែទាំ ជាពិសេសកុមារដែលងាយរងគ្រោះពីការរំលោភបំពាន។ កុមារដែលងាយរងគ្រោះទាំងនោះរួមមានកុមារពិការ កុមារជាជនជាតិភាគតិច កុមាររស់នៅតាមដងផ្លូវ កុមារគ្មានទីជម្រក និងកុមារកំពុងស្វែងរកទីជម្រក ដោយគ្រួសារពួកគេទាំងអស់នោះទទួលផលប៉ះពាល់ដោយគ្រឿងស្រវឹង គ្រឿងញៀន បញ្ហាសុភាពផ្លូវចិត្ត អំពើហិង្សាក្នុងគ្រួសារ រឺគ្រួសារមានផ្ទុកមេរោគ HIV/AIDS និងបញ្ហាសុខភាពផ្សេងៗទៀត រួមទាំងបញ្ហាប្រឈមចំពោះច្បាប់ ដូចជា ជាជនល្មើស ជាសាក្សី និងជាជនរងគ្រោះ។ ក្នុងនោះមានអង្គការជាច្រើនចូលរួម តួយ៉ាងដូចជាអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា គឺធ្វើការជាមួយកុមារ ដើម្បីផ្តល់នូវមធ្យោបាយមួយ ដើម្បីបង្កើតទំនាក់ទំនងជាមួយកុមារដែលងាយរងគ្រោះ អាស្រ័យហេតុនេះហើយ យើងត្រូវមានការប្រុងប្រយ័ត្នចំពោះបុគ្គលមួយចំនួនតូច ដែលធ្វើការបំពាននូវតួនាទីរបស់ខ្លួន ដើម្បីទៅទាក់ទងកុមារ។

LAC ការពារចំពោះកុមារទាំងឡាយណាដែលធ្វើការជាមួយនិងតំណាងរបស់ LAC រឺស្នាក់នៅរួមទីតាំងជាមួយតំណាង LAC។

LAC គឺប្តេជ្ញាចិត្តអនុវត្តតាមច្បាប់ស្តីពីសិទ្ធ និងសុខមាលភាពរបស់កុមារ។ ការអនុវត្តន៍នេះគឺស្របទៅតាមសិទ្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ ដែលអនុម័តដោយរាជរដ្ឋាភិបាលប្រទេសកម្ពុជានៅឆ្នាំ១៩៩២។ LAC យ៉ាងម៉ឺងម៉ាត់ទទួលខុសត្រូវដោយយកចិត្តទុកដាក់បំផុត អនុវត្តតាមស្តង់ដាអង្គការ ដើម្បីសុវត្ថិភាពកុមារ (CSO) ក្នុងគោលបំណងដើម្បីការពារកុមារពីភ័យអន្តរាយ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចក្នុងគ្រប់ទម្រង់ទាំងអស់ ។

៣.គោលនយោបាយ

៣.១ ទិសដៅ និងគោលបំណង